# អនុស្សរណៈយោគយល់គ្នា

## ស្តីពី

## ការចុះបញ្ជីទទួលស្គាល់ប្រកាសនីយបត្រតក្កកម្ម
## សាធារណរដ្ឋប្រជាមានិតចិន
## នៅព្រះរាជាណាចក្រកម្ពុជា

## រវាង

## ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
## នៃព្រះរាជាណាចក្រកម្ពុជា

## និង

## អង្គភាពកម្មសិទ្ធិបញ្ញារដ្ឋ
## នៃសាធារណរដ្ឋប្រជាមានិតចិន

ក្រសួងឧស្សាហកម្ម និងសិប្បកម្ម នៃព្រះរាជាណាចក្រកម្ពុជា (ដែលហៅកាត់ថា "the MIH") និងអង្គភាពកម្មសិទ្ធិបញ្ញារដ្ឋនៃសាធារណរដ្ឋប្រជាមានិតចិន (ដែលហៅកាត់ថា "the SIPO")។

- **ពិចារណា** លើតម្លៃ និងសារសំខាន់នៃកម្មសិទ្ធិបញ្ញាសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ច និងការផ្លាស់ប្តូរបច្ចេកវិជ្ជា
- **ពិចារណា** លើអនុស្សរណៈយោគយល់គ្នា ស្តីពីកិច្ចសហប្រតិបត្តិការទ្វេភាគីស្តីពីកម្មសិទ្ធិបញ្ញា រវាងក្រសួងឧស្សាហកម្ម និងសិប្បកម្ម នៃព្រះរាជាណាចក្រកម្ពុជា និងអង្គភាពកម្មសិទ្ធិបញ្ញារដ្ឋនៃសាធារណរដ្ឋប្រជាមានិតចិន ដែលបានចុះហត្ថលេខានៅថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១៧
- **ទទួលស្គាល់** សេចក្តីត្រូវការដើម្បីជំរុញធ្វើឲ្យប្រសើរឡើង និងពង្រឹងប្រព័ន្ធកម្មសិទ្ធិបញ្ញា ក្នុងទិដ្ឋភាពផ្តល់នូវការឆ្លើយតបដ៏មានប្រសិទ្ធភាពទៅនឹងភាពប្រឈមទាំងឡាយ ដែលកើតឡើងពីការប្រើប្រាស់បច្ចេកវិជ្ជាថ្មី
- **យល់ឃើញ** សម្រាប់អភិវឌ្ឍបន្ថែមទៀតនូវសហប្រតិបត្តិការរវាងអង្គភាពកម្មសិទ្ធិបញ្ញារដ្ឋចិន និងក្រសួងឧស្សាហកម្ម និងសិប្បកម្ម (ភាគីនីមួយៗចាប់ពីពេលនេះទៅហៅថា "ភាគី" ហើយភាគីទាំងពីរហៅថា "គូភាគី") ដើម្បីដោះស្រាយបញ្ហាប្រឈមនៃសតវត្សនេះ និងជំរុញការផ្លាស់ប្តូរសេដ្ឋកិច្ច រវាងកម្ពុជា និងចិន និង
- **ពិនិត្យ** ទៅលើទំហំអភិវឌ្ឍនៃកម្មសិទ្ធិបញ្ញា
- បានព្រមព្រៀងគ្នាដូចខាងក្រោម៖

## ១. កម្មវត្ថុ

គោលបំណងនៃអនុស្សរណៈយោគយល់គ្នានេះ គឺការផ្តល់នីតិវិធីលម្អិតនៃការចុះបញ្ជីទទួលស្គាល់ប្រកាសនីយបត្រតក្កកម្មចិននៅកម្ពុជា ។

## ២. សំណុំលិខិតស្នើសុំ

ក្រសួងឧស្សាហកម្ម និងសិប្បកម្ម នឹងរៀបចំទម្រង់ពាក្យស្នើសុំ និងឯកសារចាំបាច់មួយចំនួនទៀតសម្រាប់ការចុះបញ្ជីទទួលស្គាល់ប្រកាសនីយបត្រតក្កកម្មចិននៅកម្ពុជា។ សំណុំលិខិតស្នើសុំត្រូវភ្ជាប់មកជាមួយនូវឯកសារដូចខាងក្រោម៖

ក. ពាក្យសុំចុះបញ្ជី

ខ. ច្បាប់ថតចម្លងវិញ្ញាបនបត្រប្រកាសនីយបត្រតក្កកម្មចិន ដោយមានការបញ្ជាក់ថា បានចម្លងត្រឹមត្រូវតាមច្បាប់ដើម ពីអង្គភាពកម្មសិទ្ធិបញ្ញារដ្ឋចិន។

គ. ឯកសារចម្លងសេចក្តីពណ៌នាលម្អិតនៃប្រកាសនីយបត្រតក្កកម្មចិន ដោយមានការបញ្ជាក់ពីអង្គភាពកម្មសិទ្ធិបញ្ញារដ្ឋចិន ថាបានចម្លងត្រឹមត្រូវតាមច្បាប់ដើម។

ប្រសិនបើអ្នកដាក់ពាក្យសុំត្រូវតំណាងដោយភ្នាក់ងារ ពាក្យសុំចុះបញ្ជីត្រូវបញ្ជាក់ និងបង្ហាញពីឈ្មោះ និងអាសយដ្ឋានរបស់ភ្នាក់ងារនោះ និងត្រូវមានលិខិតផ្ទេរសិទ្ធិតំណាងភ្ជាប់មកជាមួយ។

## ៣. ការទទួលពាក្យសុំ និងការត្រួតពិនិត្យដំបូង

ក. ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ត្រូវទទួល និងត្រួតពិនិត្យដំបូងលើសំណុំលិខិតស្នើសុំប្រកាសនីយបត្រតក្កកម្មចិន។

ខ. ប្រកាសនីយបត្រតក្កកម្មចិន ត្រូវមានសុពលភាពការពារក្នុងអំឡុងពេលនៃការដាក់ពាក្យស្នើសុំចុះបញ្ជី។ ប្រកាសនីយបត្រតក្កកម្មចិន ត្រូវមានកាលបរិច្ឆេទសុំចុះបញ្ជីក្រោយថ្ងៃទី២២ ខែមករា ឆ្នាំ២០០៣ និងត្រូវស្របតាមប្រកាសស្តីពីការផ្តល់ប្រកាសនីយបត្រតក្កកម្មនៅកម្ពុជា។

គ. ប្រសិនបើពាក្យស្នើសុំតម្រូវឲ្យមានការកែតម្រូវ អ្នកដាក់ពាក្យសុំត្រូវសរសេរជាលាយលក្ខណ៍អក្សរសុំកែតម្រូវ ក្នុងរយៈពេល២(ពីរ)ខែ។

ឃ. កាលបរិច្ឆេទសុំចុះបញ្ជីប្រកាសនីយបត្រតក្កកម្មចិននៅកម្ពុជា គឺជាកាលបរិច្ឆេទដូចគ្នានឹងកាលបរិច្ឆេទសុំចុះបញ្ជីប្រកាសនីយបត្រតក្កកម្មនៅចិន។ កាលបរិច្ឆេទអស់សុពលភាពនៃប្រកាសនីយបត្រតក្កកម្មចិននៅកម្ពុជា គឺជាកាលបរិច្ឆេទដូចគ្នានឹងកាលបរិច្ឆេទអស់សុពលភាពប្រកាសនីយបត្រតក្កកម្មនៅចិន។

## ៤. ការចុះបញ្ជី

ក. ក្រសួងឧស្សាហកម្ម និងសិប្បកម្ម យល់ព្រមចុះបញ្ជីពាក្យសុំប្រកាសនីយបត្រតក្កកម្មចិន ដែលបានបំពេញតាមការតម្រូវនៃការត្រួតពិនិត្យដំបូង។ យោងតាមសំណើរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម អង្គភាពកម្មសិទ្ធិបញ្ញារដ្ឋចិននឹងសម្របសម្រួលដំណើរការ នៃការចុះបញ្ជីប្រកាសនីយបត្រតក្កកម្មចិន។

ខ. ប្រកាសនីយបត្រតក្កកម្មចិនដែលបានចុះបញ្ជីនៅកម្ពុជា ត្រូវបានចាត់ទុកដូចជាប្រកាសនីយបត្រតក្កកម្មដែលបានផ្តល់ យោងតាមច្បាប់នៃប្រទេសកម្ពុជាស្តីពីប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ និងគំនូរឧស្សាហកម្ម ចុះថ្ងៃទី២២ ខែមករា ឆ្នាំ២០០៣ និងច្បាប់ស្តីពីវិសោធនកម្មមាត្រា៣៧ មាត្រា៣៨ មាត្រា១០៩ និងមាត្រា១៣៦ នៃច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ និងគំនូរឧស្សាហកម្ម ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១៧។

គ. ការចុះបញ្ជីទទួលស្គាល់ប្រកាសនីយបត្រតក្កកម្មចិននៅកម្ពុជា ត្រូវបង់កម្រៃសេវាដូចមានចែងក្នុងប្រកាសរួមស្តីពីការពីការផ្តល់សេវាសាធារណ និងការពិន័យអន្តរការណ៍ជាប្រាក់ ដោយក្រសួងឧស្សាហកម្ម និងសិប្បកម្ម និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ កម្រៃប្រចាំឆ្នាំសម្រាប់ប្រកាសនីយបត្រតក្កកម្មចិនដែលបានចុះបញ្ជីទទួលស្គាល់នៅកម្ពុជា ត្រូវបង់ដោយរាប់បន្តពីកាលបរិច្ឆេទចុះបញ្ជីនៃប្រកាសនីយបត្រតក្កកម្មនោះ ដោយផ្អែកលើកាលបរិច្ឆេទសុំចុះបញ្ជីនៃប្រកាសនីយបត្រតក្កកម្ម។

ឃ. ការវិនិច្ឆ័យលើការរំលោភបំពាន លើប្រកាសនីយបត្រតក្កកម្មចិនដែលបានចុះបញ្ជីនៅកម្ពុជា ត្រូវតែដោះស្រាយទៅតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា។

ង. ប្រសិនបើពាក្យស្នើសុំប្រកាសនីយបត្រតក្កកម្ម ត្រូវបានដាក់សុំចុះបញ្ជីនៅក្រសួងឧស្សាហកម្ម និងសិប្បកម្ម ក្រោយពីបានដាក់សុំចុះបញ្ជីរួចនៅអង្គភាពកម្មសិទ្ធិបញ្ញារដ្ឋចិន ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ត្រូវសម្រេចផ្តល់ប្រកាសនីយបត្រតក្កកម្ម យោងលើសេចក្តីសម្រេចផ្តល់ប្រកាសនីយបត្រតក្កកម្មរបស់អង្គភាពកម្មសិទ្ធិបញ្ញារដ្ឋចិន។

## ៥. នីតិវិធីក្រោយការចុះបញ្ជី

ក. គូភាគីត្រូវរក្សាទំនាក់ទំនងគ្នាលើការកែសម្រួលសេចក្តីអះអាង ការអស់សុពលភាព និងការផ្លាស់ប្តូរផ្សេងទៀត នៃប្រកាសនីយបត្រតក្កកម្មដែលបានចុះបញ្ជី ក្រោយពីដំណើរការចុះបញ្ជីរួច។

ខ. ក្នុងករណីមានការបញ្ចប់សិទ្ធិប្រកាសនីយបត្រតក្កកម្មចិន ដោយសារការបង់កម្រៃមិនទាន់ពេលវេលា ប្រកាសនីយបត្រតក្កកម្មចិននៅកម្ពុជាមិនមានឥទ្ធិពលអ្វីឡើយ។

គ. ការបញ្ចប់សិទ្ធិនៃប្រកាសនីយបត្រតក្កកម្មចិននៅកម្ពុជា ត្រូវអនុវត្តបន្ទាប់ពីទទួលបានការ ជូនដំណឹងពីអង្គភាពកម្មសិទ្ធិបញ្ញារដ្ឋចិន មកក្រសួងឧស្សាហកម្ម និងសិប្បកម្ម អំពីការអស់សុពលភាពប្រកាសនីយបត្រតក្កកម្មចិន ក្រោយពីនីតិវិធីដោះស្រាយតាមផ្លូវច្បាប់ត្រូវបានបញ្ចប់។

ឃ. ក្នុងករណីមានការផ្លាស់ប្តូរលើឯកសារប្រកាសនីយបត្រតក្កកម្ម រួមមាន៖ សេចក្តីអធិប្បាយ សេចក្តីអះអាង និងខ្លឹមសារសង្ខេប នៃប្រកាសនីយបត្រតក្កកម្មចិន អង្គភាពកម្មសិទ្ធិបញ្ញារដ្ឋចិន ត្រូវជូនដំណឹងដល់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ហើយក្រសួងឧស្សាហកម្ម និងសិប្បកម្មត្រូវធ្វើការផ្លាស់ប្តូរទៅតាមការស្នើសុំ។

ង. ក្នុងករណីមានវិវាទ ប្រសិទ្ធភាពផ្លូវច្បាប់នៃប្រកាសនីយបត្រតក្កកម្មចិនដែលបានចុះបញ្ជី នៅកម្ពុជា ត្រូវដូចគ្នានឹងប្រកាសនីយបត្រតក្កកម្មចិន ក្រោយពីនីតិវិធីដោះស្រាយតាមផ្លូវច្បាប់ ត្រូវបានបញ្ចប់។ វិវាទដែលកើតមាននៅកម្ពុជា ទាក់ទងនឹងការចុះបញ្ជីប្រកាសនីយបត្រតក្កកម្មចិននៅកម្ពុជា ត្រូវដោះស្រាយដោយយោងទៅតាមច្បាប់ និងបទបប្បញ្ញត្តិនៃព្រះរាជាណាចក្រកម្ពុជា។

## ៦. ការចាប់ផ្តើមអនុវត្តការចុះបញ្ជី

ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ត្រូវចេញប្រកាសស្តីពីការចុះបញ្ជីទទួលស្គាល់ប្រកាសនីយបត្រតក្កកម្មចិននៅកម្ពុជា ហើយអង្គភាពកម្មសិទ្ធិបញ្ញារដ្ឋចិន ត្រូវចេញសេចក្តីជូនដំណឹងទៅកាន់សាធារណៈជន អំពីការចុះបញ្ជីទទួលស្គាល់ប្រកាសនីយបត្រតក្កកម្មចិននៅកម្ពុជា។

## ៧. វិសោធនកម្ម

អនុស្សរណៈយោគយល់គ្នានេះ អាចធ្វើវិសោធនកម្មបានដោយមានការយល់ព្រមជាលាយលក្ខណ៍អក្សរពីគូភាគី។

## ៨. កម្រៃសេវា

កម្រៃសេវាការងារ ដែលកើតឡើងក្នុងកំឡុងពេលអនុវត្តអនុស្សរណៈយោគយល់គ្នានេះ ត្រូវតែស្ថិតក្រោមការទទួលខុសត្រូវរបស់ភាគីនីមួយៗ។

## ៩. លក្ខណៈច្បាប់

អនុស្សរណៈយោគយល់គ្នានេះ និងសកម្មភាពសហប្រតិបត្តិការ ក្រោមអនុស្សរណៈយោគយល់គ្នានេះ គឺអាស្រ័យទៅលើច្បាប់ និងបទប្បញ្ញត្តិដែលមានជាធរមាននៃភាគីនីមួយៗ។ អនុស្សរណៈយោគយល់គ្នានេះ មិនប៉ះពាល់ដល់សិទ្ធិ និងកាតព្វកិច្ចរបស់ភាគីនីមួយៗ ក្រោមកិច្ចព្រមព្រៀងអន្តរជាតិណាមួយផ្សេងទៀត ដែលភាគីនោះត្រូវបានជាប់កិច្ចសន្យានោះទេ។

## ១០. ពេលវេលានៃការពិនិត្យឡើងវិញ

គូភាគីនឹងកំណត់ពេលវេលានៃការពិនិត្យឡើងវិញ ដើម្បីវាយតម្លៃទៅលើកិច្ចសហប្រតិបត្តិការ ក្រោមអនុស្សរណៈយោគយល់គ្នានេះ មុនដំណាច់ឆ្នាំទីមួយនៃអនុស្សារណៈនេះចូលជាធរមាន។

## ១១. រយៈពេលនិងការបញ្ចប់

ក. អនុស្សរណៈយោគយល់គ្នានេះ នឹងចូលជាធរមាន ចាប់ពីកាលបរិច្ឆេទនៃការចុះហត្ថលេខានេះដោយគូភាគី ហើយនឹងត្រូវបញ្ចប់រយៈពេលប្រាំ (៥) ឆ្នាំ។

ខ. ភាគីនីមួយៗអាចបញ្ឈប់អនុស្សរណៈយោគយល់គ្នានេះ ដោយត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរដល់ភាគីមួយទៀត យ៉ាងតិចមុនរយៈពេលសាមសិប (៣០)ថ្ងៃ។

គ. នៅពេលផុតកំណត់ ឬបញ្ឈប់អនុស្សរណៈយោគយល់គ្នានេះ គូភាគីនឹងពិគ្រោះយោបល់គ្នាទៅវិញទៅមក ហើយបញ្ជាក់ជាលាយលក្ខណ៍អក្សរ ថាតើមានបំណងបន្តសកម្មភាពកិច្ចសហប្រតិបត្តិការដែលកំពុងដំណើរការ ខណៈពេលផុតកំណត់នៃកាលបរិច្ឆេទ ឬបញ្ឈប់អនុស្សរណៈយោគយល់គ្នានេះ។

## ១២. ការពិគ្រោះយោបល់

គូភាគីនឹងពិគ្រោះយោបល់គ្នាតាមការសមស្របអំពីរឿងហេតុដែលអាចកើតឡើង ក្នុងអំឡុងពេលអនុវត្តអនុស្សរណៈយោគយល់គ្នានេះ។

## ១៣. ភាសា

ធ្វើនៅទីក្រុងភ្នំពេញ ថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១៨ ធ្វើឡើងចំនួនពីរច្បាប់ ជាបីភាសា ភាសាចិន ភាសាខ្មែរ និងភាសាអង់គ្លេស អត្ថបទទាំងអស់មានតម្លៃស្មើគ្នា។

**ក្រសួងឧស្សាហកម្ម និងសិប្បកម្ម**
**នៃព្រះរាជាណាចក្រកម្ពុជា**

**ឯកឧត្តមបណ្ឌិត ចម ប្រសិទ្ធ**
**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម**

**អង្គភាពកម្មសិទ្ធិបញ្ញារដ្ឋ**
**នៃសាធារណរដ្ឋប្រជាមានិតចិន**

**បណ្ឌិត សេន ចាងយូ**
**ប្រធានអង្គភាពកម្មសិទ្ធិបញ្ញារដ្ឋ**
**នៃសាធារណរដ្ឋប្រមានិតចិន**